# ការសម្ភាសន៍របស់អ្នកមីង មុល សារី

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ មុល សារី

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ មុល សារី</u>

សង្ខេបៈ អ្នកមីង មុល សារី គាត់មានអាយុសែសិបបីឆ្នាំ ហើយគាត់បានកើតនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ គាត់ជាកូនទីបីនៅក្នុងចំណោមបងប្អូនបួននាក់។ ឪពុករបស់គាត់ត្រូវបានពួកពលពតយកទៅវាយចោល ហើយម្តាយរបស់គាត់បានក្លាយជាស្ត្រីម៉េមាយដែលបានតស៊ូចិញ្ចឹមកូនបួននាក់ដោយមិនបានយកប្តីទៀតទេ។ ក្នុងជីវិតរបស់គាត់មានការលំបាកជាច្រើន គាត់មិនសូវបានរៀនសូត្រច្រើនទេដោយសារគាត់គ្មានឪពុកដូច្នេះគាត់ត្រូវដើរស៊ីឈ្នួលគេដើម្បីបានលុយកាក់ខ្លះដើម្បីជួយម្តាយរបស់គាត់។ គាត់បានរៀបការហើយគាត់មានកូនបីនាក់ ហើយបានធ្វើការងារយ៉ាងខ្លាំងដើម្បីកូនគាត់។ធ្វើឡើងនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០១៨។

កៈ ជាដំបូងសូមជំរាបសួរអ្នកមីង ខ្ញុំឈ្មោះគង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួន របស់ប្រជាជនកម្ពុជាដែលធ្វើឡើយដោយសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ នៅសហរដ្ឋអាមេរិច ហើយ ការសម្ភាសន៍របស់យើងនេះថ្ងៃឡើងនៅថ្ងៃទី១៥ ខែ០៤ ឆ្នាំ២០១៨ ហើយសំរាប់ការសម្ភាសន៍មួយ នេះអ្នកមីង យើងនឹងថតជាសំលេង ហើយនឹងថតរូបរបស់អ្នកមីង ដើម្បីយើងយកទៅដាក់នៅលើ វេបសាយរបស់សាកលវិទ្យាល័យប៊ី វ៉ាយ យូ ហើយអញ្ចឹង តើអ្នកមីងអនុញ្ញាត្តិអោយពួកយើង យក សំលេងហើយនឹងរូបភាពរបស់អ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ទេអ្នកមីង?

ខៈ ខ្ញុំមានថាអី យកទៅដាក់ទៅ។

កៈ ហើយអញ្ចឹង អរគុណហើយអ្នកមីងដែលផ្ដល់ពេលវេលាអោយខ្ញុំសម្ភាសន៍និងអនុញ្ញាតិអោយ
ខ្ញុំយកសំលេងនិងរូបភាពអ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង ជាដំបូង តើអ្នកមីងមានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ខ្ញុំឈ្មោះ មុល សារី។

កៈ មុល សារី! ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេអ្នកមីង?

ខៈ អត់មានទេ។

កៈ ហើយអញ្ចឹង កាលនៅពីក្មេងៗ តើគេហៅឈ្មោះរបស់អ្នកមីងថាម៉េចដែរ អ្នកមីង?

ខៈ គ្មានទេ គេហៅតែឈ្មោះខ្ញុំនឹង មិនដែលហៅអ្វីផ្សេងទេ។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង សព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ សព្វថ្ងៃនេះខ្ញុំមានអាយុសែសិបបីឆ្នាំ។

កៈ សែសិបបីឆ្នាំ! ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងនៅចាំថ្ងៃខែឆ្នាំកំណើតរបស់អ្នកមីងទេ?

ខៈ អត់ចាំទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំឆ្នាំជាឆ្នាំខ្មែរទេ?

ខៈ ខ្ញុំកើតឆ្នាំថោះ។

កៈ អូ! អ្នកមីងកើតក្នុងឆ្នាំថោះ។ ហើយអញ្ចឹង
តើអ្នកមីងមានទីកន្លែងកំណើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ខ្ញុំកើតនៅក្នុងភូមិផ្នត់ដំរីយើងនឹង។

កៈ ហើយអញ្ចឹង តើអ្នកមីងអាចជួយប្រាប់ឈ្មោះទីតាំងច្បាស់លាស់បានទេអ្នកមីង?

ខៈ ភូមិផ្នត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

កៈ ហើយអញ្ចឹង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខៈ ខ្ញុំមានបងប្អូនចំនួនបួននាក់។

កៈ ហើយអញ្ចឹង តើអ្នកមីងជាកូនទីប៉ុន្មានដែរនៅក្នុងក្រុមគ្រួសាររបស់អ្នកមីង?

ខៈ ខ្ញុំជាកូនទីបី។

កៈ ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះបងប្អូនរបស់អ្នកមីងទាំងអស់បានទេអ្នកមីង?

ខៈ បងគេបង្អស់ឈ្មោះ ម៉ាន់ សារិន បន្ទាប់មកឈ្មោះ ម៉ាន់ សារឿន ហើយបន្ទាប់មកខ្ញុំឈ្មោះ មុល សារី ហើយប្អូនពៅឈ្មោះ ម៉ាន់ ចក់។

កៈ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំសាច់រឿងពីខ្សែជីវិតរបស់បងប្អូនរបស់អ្នកមីងទេ?

ខៈ អត់ចាំទេ ព្រោះអីខ្ញុំមិនសូវដឹងទេ។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយពួកគាត់ពេលដែលអ្នកមីង នៅក្មេងៗ?

ខៈ គ្មានធ្វើអីទេ មានដែលធ្វើស្រែចំការ មើលគោមើលក្របី។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើបងប្អូនរបស់អ្នកមីងពួកគាត់រស់នៅកន្លែងណាដែរអ្នកមីង?

ខៈ បងប្អូនរបស់ខ្ញុំគាត់រស់នៅក្នុងភូមិនឹងទាំងអស់គ្នា។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើបងប្អូនរបស់អ្នកមីង គាត់ប្រកបមុខរបរអ្វីដែរអ្នកមីង?

ខៈ បងប្អូនខ្ញុំគាត់ធ្វើតែស្រែដូចតែគ្នានឹង គ្មានធ្វើអីទេ ប្រកបមុខរបរតែធ្វើស្រែនឹង។

កៈ ហើយអញ្ចឹង តើម្តាយរបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ អំ វ៉ាត។

កៈ អំ វ៉ាត! ហើយអញ្ចឹង តើឪពុករបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ម៉ាន់ មុល។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើឪពុកម្តាយរបស់អ្នកមីងគាត់មានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំអត់សូវដឹងទេ ព្រោះឪពុករបស់ខ្ញុំគាត់បានស្លាប់តាំងពីជំនាន់ពលពតមកម្លេះ ហើយម្តាយខ្ញុំនៅមេម៉ាយរហូតមកដល់សព្វថ្ងៃនេះ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់មានអាយុប៉ុន្មានហើយអ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់អាយុហុកជាងហើយ តែហុកប៉ុន្មានខ្ញុំអត់ដឹងដែរ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់កើតឆ្នាំណាដែរ អ្នកមីង?

ខៈ ខ្ញុំអត់ដឹងគាត់កើតឆ្នាំណាទេ តែគ្រាន់តែដឹងថាគាត់កើតឆ្នាំខាល អាយុហុកជាង។

កៈ ឆ្នាំខាល អាយុហុកជាង! ហើយអញ្ចឹង
តើអ្នកមីងមានចាំទេថាគាត់បានកើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់កើតនៅនឹងភូមិផ្ទត់ដំរីខាងត្បូងដែរ។

កៈ ហើយអញ្ចឹងសំរាប់ឪពុករបស់អ្នកមីងគាត់បានស្លាប់ហើយ?

ខៈ បាទ ឪពុករបស់ខ្ញុំគាត់បានស្លាប់តាំងពីជំនាន់ដែលគេថាយកទៅរៀនទៅសូត្រណោះ
(យកទៅរៀនទៅសូត្រមានន័យថាគេយកមនុស្សទៅវាយសំលាប់ចោល)។

កៈ ហើយអញ្ចឹង តើអ្នកមីងដឹងពីមូលហេតុដែលគេយកគាត់ទៅសំលាប់ទេ?

ខៈ ឪពុករបស់ខ្ញុំគាត់ធ្លាប់ធ្វើការ រួចហើយគេយកទៅរៀន
ហើយក៏បាត់រហូតមកដល់ឥលូវនឹងទៅ។

កៈ អញ្ចឹងមានន័យថាការទៅរៀននឹងមានន័យថាគេយកគាត់ទៅសំលាប់ចោល។

ខៈ តាំងពីខ្ញុំមិនទាន់ដឹងក្ដី នៅតូចពេលហ្នឹងខ្ញុំមានអាយុពីរឆ្នាំ
ហើយប្អូនខ្ញុំអាយុប្រាំពីរខែនៅក្នុងពោះម្ដាយរបស់ខ្ញុំ។

កៈ នៅក្នុងពោះម្ដាយរបស់អ្នកមីង។ ហើយអញ្ចឹង តើឪពុកម្ដាយរបស់អ្នកមីង
គាត់រកស៊ីអ្វីដើម្បីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខៈ ឪពុកម្ដាយរបស់ខ្ញុំគាត់ដើរស៊ីឈ្នួលគេ។

កៈ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់អ្នកមីងគាត់ជាមនុស្សដូចម្ដេចដែរអ្នកមីង?

ខៈ ឪពុកម្ដាយរបស់ខ្ញុំគាត់ជាមនុស្សស្លូតត្រង់ណាស់ ដើរស៊ីឈ្នួលគេដើម្បីចិញ្ចឹមកូន។

កៈ ហើយអញ្ចឹង តើអ្នកមីងនៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងទេ?

ខៈ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំគាត់ឈ្មោះ តាអំ យាយស៊ូ។

កៈ ហើយអញ្ចឹង តើអ្នកមីងនៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខៈ ជីដូនជីតាខាងឪពុករបស់ខ្ញុំឈ្មោះតាម៉ាន់ យាយយីម។

កៈ ហើយអញ្ចឹង តើអ្នកមីងដឹងទេថាពួកគាត់បានកើតនៅពេលណាទេ?

ខៈ ពួកគាត់កើតនៅភូមិនឹង តែខ្ញុំអត់ដឹងថាពួកគាត់កើតនៅពេលណាទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងមានធ្លាប់ដឹងពីរឿងខ្សែជីវិតរបស់ជីដូនជីតារបស់អ្នកមីងទេ?

ខៈ ខ្ញុំអត់ដឹងដែរ ដោយសារកាលនឹងខ្ញុំនៅក្មេងៗណាស់។

កៈ ហើយអញ្ចឹង តើអ្នកមីងមានបងប្អូនឬមួយក្រុមគ្រួសារដែលរស់នៅខេត្តផ្សេងទេ?

ខៈ អត់មានទេ មានតែស្លាប់អស់ហើយនៅជំនាន់ពលពត។

កៈ ហើយអញ្ចឹង តើអ្នកមីងមានសាច់ញាត្តិដែលរស់នៅក្រៅប្រទេសខ្មែរយើងទេ?

ខៈ មានប្អូនរបស់ឪពុកខ្ញុំមួយ ទៅបាត់ទៅបានដំណឹងថាគាត់នៅខេត្តកំពង់ឆ្នាំង តែទៅបាត់ដំណឹងរហូតមកដល់ឥឡូវនឹង គាត់ឈ្មោះម៉ាន់ មៀត។

កៈ ហើយអញ្ចឹង សំរាប់ស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ វន្ត នៅ។

កៈ ហើយអញ្ចឹង តើស្វាមីរបស់អ្នកមីង គាត់បានកើតនៅកន្លែងណាដែរអ្នកមីង?

ខៈ ស្វាមីរបស់ខ្ញុំគាត់កើតនៅភូមិក្រពើសារ ឃុំដំរិល ស្រុកអូររាំង ខេត្តត្បូងឃ្មុំ។

កៈ ហើយអញ្ចឹង តើអ្នកមីងមានចាំទេថា អ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅពេលណាទេ អ្នកមីង?

ខៈ ខ្ញុំចាំតែថាខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅក្នុងឆ្នាំច។

កៈ ហើយអញ្ចឹង មកដល់សព្វថ្ងៃនេះ តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់បានរយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ មកដល់សព្វថ្ងៃនេះខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់បានម្ភៃបីឆ្នាំហើយ។

កៈ អូ! យូរដែលហើយ! ហើយអញ្ចឹង តើអាពាហ៍ពិពាហ៍មួយនឹងត្រូវបានរៀបចំឡើងដោយឪពុក ម្តាយរបស់អ្នកមីងមែនទេ?

ខ៖ ហ្នឹងហើយ ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំទេថា ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង ដូចជាមានថ្លៃជំនូនទេអ្នកមីង?

ខ៖ មានបន្តិចបន្តួចនឹងជំនាន់នឹង។

ក៖ ហើយអញ្ចឹង តើថ្លៃជំនូនប៉ុន្មានដែរអ្នកមីង?

ខ៖ បន្តិចនឹង ថាទទេម៉ងទៅ ព្រោះអីតិចណាស់។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចប្រាប់ខ្ញុំបានទេ ពេលដែលអ្នកមីងហើយនឹងប្ដីរបស់អ្នកមីងបានជួបគ្នាជាលើកដំបូង?

ខ៖ ខ្ញុំតាមម្ដាយ ខ្ញុំមិនដែលស្គរគាត់ប្ដីរបស់ខ្ញុំទេ តែម្ដាយរបស់ខ្ញុំគាត់លើកអោយគេទៅ ខ្ញុំធ្វើតាមគាត់ទៅ នឹកឃើញថាគាត់ម៉េមាយហើយ យើងធ្វើតាមគាត់ទៅកុំអោយគាត់ពិបាកចិត្តដោយសារយើងទៀត ព្រោះអីយើងនៅក្រោមបង្គប់ម្ដាយយើងចិញ្ចឹមថែរក្សា បើម្ដាយគាត់រៀបចំទុកដាក់អោយ យើងហើយក៏យកតាមគាត់ទៅ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានកូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ខ្ញុំមានកូនចំនួនបីនាក់។

ក៖ ហើយអញ្ចឹង តើកូនអ្នកមីងទាំងបីអ្នកមានឈ្មោះអ្វីខ្លះដែរអ្នកមីង?

ខ៖ បងគេឈ្មោះនៅ សំណាង ហើយបន្ទាប់ឈ្មោះនៅ ស៊ីណាត ហើយនឹងប្អូនគេឈ្មោះនៅ       ដាណែត។

ក៖ ហើយអញ្ចឹង សំរាប់កូនរបស់អ្នកមីង តើមានប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ កូនរបស់ខ្ញុំមានប្រុសពីរនាក់ ហើយស្រីម្នាក់ កូនពៅជាកូនស្រី។

ក៖ ហើយអញ្ចឹង សំរាប់កូនទីមួយរបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ កូនទីមានរបស់ខ្ញុំគាត់មានអាយុម្ភៃបីឆ្នាំហើយ។

ក៖ ហើយអញ្ចឹង តើអ្នកមីងចាំថាគាត់បានកើតនៅក្នុងឆ្នាំណាទេអ្នកមីង?

ខ៖ មិនដឹងជាគាត់កើតនៅឆ្នាំណាទេ ដឹងតែឆ្នាំខ្មែរ គាត់កើតឆ្នាំកុរ។

ក៖ ហើយអញ្ចឹងសំរាប់កូនទីពីររបស់អ្នកមីង តើគាត់កើតនៅពេលណាដែរអ្នកមីង?

ខ៖ កូនទីពីររបស់ខ្ញុំគាត់កើតនៅឆ្នាំខាល អាយុម្ភៃឆ្នាំហើយ។

ក៖ ម្ភៃឆ្នាំហើយឆ្នាំនឹង! ហើយអញ្ចឹងសំរាប់កូនទីបីរបស់អ្នកមីងវិញ?

ខ៖ អាយុដប់បីឆ្នាំហើយ គាត់កើតឆ្នាំរកា។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីងធ្លាប់មានអនុស្សាវរីយ៍ល្អៗជាមួយកូនរបស់អ្នកមីងទេ?

ខ៖ មានស្រឡាញ់រាប់អានថៃរក្សា ប្រដៅកុំអោយដើរផ្លូវខុសអោយដើរតាមផ្លូវល្អ
កុំអោយសង្គមគេស្អប់ខ្ពើម អោយជៀសវាងគ្រឿងញៀន ឆក់ប្លន់
ការបង្ហោះម៉ូតូអីដែលគេស្អប់ខ្ពើម ប្រដៅថៃរក្សាកូន ស្រឡាញ់ចឹង។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានចេះអាន និងសរសេរអក្សរខ្មែរទេអ្នកមីង?

ខ៖ ចេះនឹងស្ទាក់ស្ទើរណាស់ព្រោះអីអត់សូវបានរៀនសូត្រ
ម្ដាយគ្មានលុយគ្មានកាក់អោយទៅរៀន ទៅរៀនផងឈប់ផង ដើរទៅមើលគោមើលអី
គ្មានបានរៀនណាជ្រៅជ្រះនឹងគេទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានចេះនិយាយភាសាផ្សេងៗក្រៅពីភាសាខ្មែរទេ អ្នកមីង?

ខ៖ មិនចេះទេ ស្អីក៏មិនចេះដែរ។

ក៖ ហើយអញ្ចឹង កាលដែលអ្នកមីងនៅតូច
តើអ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរអ្នកមីង?

ខ៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទីបីទីបួននឹង ប៉ុន្តែគ្មានលុយគ្មានកាក់រៀន
ម្ដាយរកស៊ីម្នាក់ឯងគ្មានលុយ អោយរៀននឹងគេ។

ក៖ ហើយអញ្ចឹង កាលដែលអ្នកមីងរៀននឹង តើអ្នកមីងរៀននៅសាលាណាដែរ អ្នកមីង?

ខ៖ ខ្ញុំរៀននៅសាលាដំរិលយើងនឹង។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងធ្លាប់មានមិត្តភក្តិស្និតស្នាលដែលបានធំធាត់មកជាមួយគ្នាទេ អ្នកមីង?

ខ៖ ថីមិនមាន តែឥលូវបែកខ្វែកគ្នាអស់ហើយ គេមានប្ដីមានប្រពន្ធរៀងៗខ្លួនអស់ហើយ គេទៅបាត់អស់ទៅសំរាប់គេ ម្ដាយឪពុកគេមាន ហើយសំរាប់យើងគ្មានទៅណាមិនរួចនឹងគេទេ ខ្វះខាតមុខក្រោយរកអីទីពឹងមិនបាន បានល្ងាចខ្វះព្រឹក ហើយបានព្រឹកខ្វះល្ងាច។

ក៖ ហើយអញ្ចឹង មិត្តភក្តិរបស់អ្នកមីងនឹង តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះ មៀន សុខគង់។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានចាំថាអ្នកមីងចូលចិត្តធ្វើអ្វីជាមួយពួកគាត់ទេ?

ខ៖ មានចូលចិត្តអីក្រៅពីដើរស៊ីឈ្នួលគេ ធ្វើស្រែស្ទូងបង្វាស់ដៃគ្នានឹង។

ក៖ អូ! អញ្ចឹងមានន័យថាអ្នកមីងចូលចិត្តធ្វើការជាមួយគ្នា។ ហើយអញ្ចឹង តើសព្វថ្ងៃនេះអ្នកមីងមានធ្វើស្រែចំការទេអ្នកមីង?

ខ៖ មានធ្វើស្រែបន្តិចបន្តួចនឹងណា។

ក៖ អូ! ធ្វើស្រែបន្តិចបន្តួចអ្នកមីង។ ហើយអញ្ចឹង ក្រៅពីអ្នកមីងធ្វើស្រែបន្តិចបន្តួចនឹង តើអ្នកមីងមានធ្វើអ្វីទៀតដើម្បីរកប្រាក់កំរៃដើម្បីចិញ្ចឹមក្រុមគ្រួសារទេអ្នកមីង?

ខ៖ បន្ទាប់ពីធ្វើស្រែរួច ដើរស៊ីឈ្នួលគេ កោសដំឡូងទៅ បេះម្រេច គេជួលអីទៅនឹងហើយ អោយតែគេជួលយើង អោយតែបានលុយយកមកចិញ្ចឹមកូនចិញ្ចឹមចៅ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងគិតថាជីវិតរបស់អ្នកមីងតាំងពីក្មេងរហូតមកដល់ពេលនេះ ជីវិតរបស់អ្នកមីងមានការផ្លាស់ប្ដូរទេ?

ខ៖ មិនទៅសង្ឃឹមទេ តែចេះតែតស៊ូទៅព្រោះយើងអត់មានឪពុកអីទីពឹងនឹងគេ បើយើងកំព្រា តែចេះតែតស៊ូទៅអោយតែបានមួយរស់ៗ មើលទៅគ្មានសង្ឃឹមថាបានថ្កុំថ្កើននឹងគេទេរាល់ថ្ងៃនឹង បានអោយតែកូនរស់មើលគេមើលឯងចឹងទៅ។

ក៖ ហើយអញ្ចឹង សំរាប់ម្ហូប តើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេអ្នកមីង?

ខ៖ ម្ហូបធម្មតា គ្មានចូលចិត្តអីមានតែសម្លយើងត្រីធម្មតានឹង។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើមានល្បែងប្រជាប្រិយខ្មែរណាដែលអ្នកមីងចូលចិត្តលេងទេអ្នកមីង?

ខ៖ ធ្លាប់លេងបោះឈូង ល្បែងបីដកមួយ ហើយបើថាខាងរាំអីអត់សូវចូលចិត្តទេ ព្រោះអីអត់ដែរសូវចេះ។

ក៖ ហើយអញ្ចឹង តើនៅក្នុងក្រុមគ្រួសាររបស់អ្នកមីង មាននរណាដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេអ្នកមីង?

ខ៖ ក្នុងក្រុមគ្រួសារខ្ញុំគ្មាននរណាចេះលេងទេ។

ក៖ ហើយអញ្ចឹង តើផ្ទះរបស់អ្នកមីងកាលនៅក្មេង មានលក្ខណៈយ៉ាងម៉េចដែរអ្នកមីង?

ខ៖ ផ្ទះពិបាកដែរនឹង ផ្ទះនៅតាំងពីអើយមក ផ្ទះតាំងពីកេរឃាយតាមក ផ្ទះមិនគប្បីនឹងគេទេ។

ក៖ ហើយអញ្ចឹង តើផ្ទះនឹងជាផ្ទះទាបនៅនឹងដីឬមួយផ្ទះខ្ពស់ដែរអ្នកមីង?

ខ៖ ជាផ្ទះខ្ពស់ជណ្ដើរបួនប្រាំកាំ។

ក៖ ហើយអញ្ចឹង តើផ្ទះមួយនឹងឪពុកម្ដាយរបស់អ្នកមីងដោយខ្លួនឯងឬមួយជួលគេអោយធ្វើអោយអ្នកមីង?

ខ៖ ខ្ញុំមិនសូវដឹងទេ ព្រោះផ្ទះនឹងគេពីដូនតាមក កើតមករស់នៅលើផ្ទះនឹងហើយ។

ក៖ អូ! អញ្ចឹងមានន័យថាពេលដែលអ្នកមីងកើតមកមានផ្ទះនឹងហើយ។ ហើយអញ្ចឹង តើអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារអ្នកមីងដូចជាវេញល្បើផ្ដៅ ឬមួយក្ងរស្កុរត្នោតអីទេអ្នកមីង?

ខ៖ គ្មានទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានពេលដែលលំបាកជាងគេទេអ្នកមីង?

ខ៖ ថីមិនមានការលំបាកនោះ លំបាកតាំងពីខ្ញុំនៅតូចៗម្លេះ តូចៗគ្មានអីនឹងគេដើរស៊ីឈ្នួលគេ យើងគ្មានគោគ្មានក្របីយើងប្រវ៉ាសដៃជាមួយគេចឹង យើងទៅស្ទូងអោយគេទៅ គេមកភ្ជួរអោយយើងព្រោះយើងម្ដាយម៉េមាយគ្មានអ្នកជួយមើលខុសត្រូវទេ បើនិយាយតាមជីវិតនឹងវាពិបាកមែនទែន។

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗដូចជា ការរៀបអាពាហ៍ពិពាហ៍បងប្អូន ឬកូនចៅ ឬមួយបុណ្យទាននៅក្នុងផ្ទះទេអ្នកមីង?

ខ៖ ធ្លាប់មានតើ រៀបអាពាហ៍ពិពាហ៍ប្អូន ក្មួយ ធ្វើបុណ្យទានអ្នកជិតខាងអីចឹង
យើងទៅជួយតាមសុំស្មើរដែលគេមករកយើងជួយ
បើគេមករកហើយយើងចេះតែជួយទៅ។

ក៖ ហើយអញ្ចឹង
តើអ្នកមីងមានអារម្មណ៍ដូចម្ដេចដែរពេលដែលអ្នកមីងទៅជួយពួកគាត់ចឹង?

ខ៖ មានអារម្មណ៍សប្បាយទៅ ពេលដែលបានទៅលេងសើចជាមួយគេជាមួយឯង។

ក៖ ហើយអញ្ចឹង កាលដែលអ្នកមីងនៅក្មេង តើអ្នកមីងធ្លាប់មានក្ដីសង្ឃឹមថា
ពេលដែលអ្នកមីងធំឡើងអ្នកមីងចង់ធ្វើអ្វីមួយទេ?

ខ៖ អត់មានសង្ឃឹមទេ ព្រោះនឹកឃើញថាយើងអត់មានឪពុក អត់ហ៊ានសង្ឃឹមទេ
ព្រោះអត់មានលុយរៀន កង់ក៏គ្មានជិះអញ្ចឹងក៏ឈប់រៀនទៅ។

ក៖ ហើយអញ្ចឹង បើសិនជាអ្នកមីងចង់ផ្ដាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយ
តើអ្នកមីងនឹងផ្ដាំផ្ញើរអ្វីខ្លះទៅកាន់ពួកគាត់?

ខ៖
ខ្ញុំប្រាប់ទៅកូនចៅជំនាន់ក្រោយអោយខំប្រឹងប្រែងរៀនសូត្រកុំអោយល្ងង់ដូចខ្ញុំមិនដឹងជារកស៊ីអីទេ អោយប្រឹងរៀនប្រឹងសូត្រទៅអោយបានការងារធ្វើនឹងគេកុំអោយពិបាក។

ក៖ ហើយអញ្ចឹង បើសិនអ្នកមីងចង់អោយកូនចៅរបស់អ្នកមីងជៀសវាង
តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរអ្នកមីង?

ខ៖ ជៀសវាងពីការលំបាកដូចខ្ញុំចឹង កុំអោយដើរតែស៊ីឈ្នួលគេចឹង
អោយរៀនសូត្រចេះដឹងនឹងគេឡើងអោយមានប្រាក់ខែនឹងគេ
ហើយចង់អោយកូនចៅជំនាន់កុំអោយជក់គ្រឿងញៀន
អោយជៀសវាងពីគ្រឿងញៀនអោយផុតគ្រែងសង្គមគេស្អប់ខ្ពើមខូចអនាគតដល់កូនខ្មែរ។

ក៖ ហើយចុងក្រោយនេះ
ខ្ញុំសូមអរគុណអ្នកមីងសំរាប់ពេលវេលាដើម្បីអោយខ្ញុំសម្ភាសន៍អ្នកមីងអំពីខ្សែជីវិតដ៏លំបាករបស់អ្នកមីង ហើយខ្ញុំសូមជូនពរអ្នកមីងសូមអោយអ្នកមីងមានសុខភាពល្អ
មានកំលាំងមាំមួន ហើយថាអ្នកមីងនឹងជោគជ័យគ្រប់មុខរបររកស៊ី
ហើយសូមជូនពរអ្នកមីងថា ស្រែចំការរបស់អ្នកមីងដែលធ្វើទៅនឹងបានទទួលផលច្រើន
ហើយខ្ញុំសង្ឃឹមថាការសម្ភាសន៍មួយនេះនឹងជួយដល់កូនចៅជំនាន់ក្រោយរបស់អ្នកមីងថាពួកគេនឹងរៀនអំពីជីវិតរបស់អ្នកមីង

ហើយពួកគាត់នឹងស្តាប់តាមការណែនាំឬក៏ការផ្តែផ្តាំរបស់អ្នកមីងដើម្បីអោយកូនចៅអ្នកមីងគាត់អាចជៀសផុតពីឧបសគ្គទាំងឡាយដែលអ្នកមីងធ្លាប់ជួបប្រទះ។ អរគុណច្រើន។